ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៥៩.១៤.០២៦.៥៧០.ស.ជ.ណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ជំនួបពិភាក្សាជាមួយតំណាងបុគ្គលដែលអះអាងថា មានជាប់ពាក់ព័ន្ធនឹង អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ៉ន ផេ ម.ក និង គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក

នាព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦ ធនាគារជាតិនៃកម្ពុជា បានទទួលជួបជាមួយតំណាងបុគ្គលដែលអះអាងថា មានជាប់ពាក់ព័ន្ធជាមួយនឹង អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ៉ន ផេ ម.ក ចំនួន ១០ រូប និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក ចំនួន ១០ រូប ក្រោមកិច្ចពិភាក្សាដូចខាងក្រោម៖

១/- ករណីអតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ៉ន ផេ ម.ក៖ ធនាគារជាតិនៃកម្ពុជា បានបញ្ជាក់ជូនតំណាងទាំង ១០ រូប ពីជំហរ និងកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរកដំណោះស្រាយជូនបុគ្គលពាក់ព័ន្ធ។ សូមបញ្ជាក់ថាអតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ៉ន ផេ ម.ក ត្រូវបានបញ្ចប់ការជម្រះបញ្ជី និងដោះស្រាយជូនម្ចាស់បំណុលរួចរាល់ហើយ។ ទន្ទឹមនេះ អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ៉ន ផេ ម.ក ក៏ត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មតាមរយៈលិខិតលេខ ១០៨១ ព.ណ.ចបព ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ របស់ក្រសួងពាណិជ្ជកម្មផងដែរ។ ដូចនេះ រាល់ការអះអាងថាជាម្ចាស់បំណុលរបស់អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ៉ន ផេ ម.ក ក្រោយពេលដែលត្រូវបានដកអាជ្ញាបណ្ណនិងរំលាយ មិនស្ថិតក្រោមសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជាឡើយ។ ទោះយ៉ាងណាបុគ្គលដែលអះអាងនៅមានសិទ្ធស្របច្បាប់ក្នុងការស្វែងរកដំណោះស្រាយតាមយន្តការតុលាការ និងច្បាប់ជាធរមាន។

២/- ករណីគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក៖ ធនាគារជាតិនៃកម្ពុជា បានបញ្ជាក់ជូនតំណាងទាំង ១០ រូប ថា គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក ត្រូវបានដកហូតអាជ្ញាបណ្ណកាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ និងបានតែងតាំងក្រុមហ៊ុនជម្រះបញ្ជីនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។ ជាមួយគ្នានេះ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ ក្រុមហ៊ុនជម្រះបញ្ជីក៏បានប្រកាសជាសាធារណៈជម្រាបដល់ម្ចាស់បំណុលទាំងអស់របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក ដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងៗនៅក្នុងរយៈពេល ៣០ថ្ងៃ តាមរយៈអាសយដ្ឋានស្ថិតនៅបុរីពិភពថ្មី ផ្សារដើមហុយ ផ្ទះលេខ៤៦ ផ្លូវលេខ៩ ភូមិពោងចក្រ សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា សូមស្នើឱ្យម្ចាស់បំណុលពាក់ព័ន្ធបន្តចូលរួមសហការជាមួយក្រុមហ៊ុនជម្រះបញ្ជី។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ទោះបីជាកិច្ចប្រជុំពិភាក្សាត្រូវបានបញ្ចប់ និងបានជូនព័ត៌មានច្បាស់លាស់ក៏ដោយ ក៏បុគ្គលដែលពាក់ព័ន្ធនឹងអតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហ្វយវែ ផេ ម.ក និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ ស៊ីវីស ម.ក ប្រមាណជា ២០០រូប នៅតែបន្តបង្កបាតុភាពនៅមុខអគារធនាគារជាតិនៃកម្ពុជា ខណ្ឌសែនសុខ។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជា សូមអំពាវនាវដល់បុគ្គលពាក់ព័ន្ធបន្តស្វែងរកដំណោះស្រាយដោយសន្តិវិធី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន និងអាជ្ញាធរពាក់ព័ន្ធ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៨០ ១៨៤
nbccommunications@nbc.gov.kh | www.nbc.gov.kh

ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_